**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ៖ បព ១៧/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

## ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន បានរៀបចំទស្សនកិច្ចទៅខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានរៀបចំដំណើរទស្សនកិច្ចទៅកាន់ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប នៅថ្ងៃទី១ និងទី២ ខែសីហា ឆ្នាំ២០២៥ ដោយមានការចូលរួមពីប្រធាន តំណាងស្ថានបេសកកម្មការទូត និងទីភ្នាក់ងារជំនាញរបស់អង្គការសហប្រជាជាតិ (អ.ស.ប) ដែលមានចំនួនសរុប២៦រូប។

គណៈប្រតិភូបានចុះទៅពិនិត្យស្ថានភាពជាក់ស្តែងនៅតំបន់ចំនួនពីរគឺ នៅភូមិថ្មដូន និងភូមិតាមាន់សែនជ័យ ឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដែលមានហេដ្ឋារចនាសម្ព័ន្ធស៊ីវិលជាច្រើនរួមមានផ្ទះប្រជាពលរដ្ឋ សាលារៀន មណ្ឌលសុខភាព ទីសក្ការៈបូជា និងវត្តអារាម ត្រូវបានបំផ្លិចបំផ្លាញដោយសារ ការទម្លាក់គ្រាប់បែក និងគ្រាប់ផ្លោងរបស់ថៃ ក្នុងអំឡុងពេលជម្លោះព្រំដែនកម្ពុជា-ថៃ នាពេលថ្មីៗនេះ នៅមុនពេលបទឈប់បាញ់ថ្ងៃទី២៨ខែកក្កដា ចូលជាធរមាន។

គណៈប្រតិភូបានចុះសួរសុខទុក្ខជនភៀសសឹកចំនួន៤៤០គ្រួសារ នៅវត្តភ្នំថ្មកំបោរ ភូមិពោធិ៍ចាស់ ឃុំបេង ខេត្តឧត្តរមានជ័យ និងចំនួន៦៩០គ្រួសារ នៅវត្តប្រាសាទបន្ទាយស្រី ស្រុកសូទ្រនិគម ខេត្តសៀមរាប ដែលកំពុងស្នាក់នៅបណ្តោះអាសន្ននៅទីតាំងទាំងពីរនេះ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយកម្ពុជាបានឱ្យដឹងថា មានគ្រួសារសរុបចំនួន៤០.៨៧០ ស្មើនឹង១៣៦.០១៣ នាក់ មកពីខេត្តជាប់ព្រំដែនចំនួនប្រាំដែលរងផលប៉ះពាល់ បានបាត់បង់ទីលំនៅដ្ឋាន។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន បានពាំនាំនូវសេចក្តីស្រឡាញ់ សមានចិត្តដ៏ជ្រាលជ្រៅ និងការចូលរួមរំលែកទុក្ខរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជូនបងប្អូនទាំងអស់ ដែលបានរងផលប៉ះពាល់ដោយសារជម្លោះព្រំដែននាពេលថ្មីៗនេះ ជាពិសេសជូនគ្រួសារជនស៊ីវិល និងកងកម្លាំងប្រដាប់អាវុធដែលបានពលី ឬរងរបួស។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានបញ្ជាក់ជូនបងប្អូនជនភៀសសឹកនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាល ក្នុងកិច្ចខិតខំប្រឹងប្រែងអស់ពី


អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

លទ្ធភាព ក្នុងការជួយសម្រាលការលំបាករបស់បងប្អូន និងការវិលត្រលប់ទៅលំនៅដ្ឋានវិញដោយសុវត្ថិភាព អោយបានឆាប់តាមដែលអាចធ្វើទៅបាន ដោយធានានូវបទឈប់បាញ់ពេញលេញ និងប្រកបដោយប្រសិទ្ធភាព។

សមាជិកអង្គទូត និងភ្នាក់ងារជំនាញរបស់អ.ស.ប ដែលបានចូលរួមក្នុងទស្សនកិច្ចនេះបានចូលរួមរំលែកទុក្ខយ៉ាងក្រៀមក្រំចំពោះក្រុមគ្រួសារជនរងគ្រោះ ដែលបាត់បង់មនុស្សជាទីស្រឡាញ់របស់ខ្លួន ហើយបានសម្តែងការអាណិតអាសូរយ៉ាងស្មោះជូនចំពោះបងប្អូន ដែលរងផលប៉ះពាល់ដោយការប៉ះទង្គិចប្រដាប់អាវុធនេះ។ គណៈប្រតិភូបានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការគោរព និងការអនុវត្តកិច្ចព្រមព្រៀងបទឈប់បាញ់អោយបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព ដែលជាជំហានដ៏សំខាន់មួយឆ្ពោះទៅសម្រេចបានដំណោះស្រាយដោយសន្តិវិធី និងយូរអង្វែង។ ជារួម សមាជិកអង្គទូត និងភ្នាក់ងារជំនាញ បានសម្តែងនូវក្តីសង្ឃឹមថាសន្តិភាពពេញលេញនឹងត្រូវបានស្តារឡើងវិញក្នុងពេលឆាប់ៗនេះ ហើយបានស្វាគមន៍ចំពោះកិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ (ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី ៧ ខែសីហាឆ្នាំ២០២៥)។ សមាជិកអង្គទូត និងភ្នាក់ងារជំនាញរបស់អ.ស.ប ក៏បានគាំទ្រយ៉ាងមុតមាំចំពោះការបន្តកិច្ចសន្ទនារវាងកម្ពុជា និងថៃ ក្នុងការសម្រេចបានសន្តិភាពយូរអង្វែង ដើម្បីអនុញ្ញាតឱ្យបងប្អូនជនភៀសសឹកអាចត្រឡប់ទៅលំនៅដ្ឋានវិញ និងបន្តជីវភាពរស់នៅប្រកបដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ។

ក្នុងដំណើរទស្សនកិច្ចនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** ក៏មានកម្មវិធីដាច់ដោយឡែកមួយទៀត ដោយបានអញ្ជើញទៅសួរសុខទុក្ខ និងប្រគល់អំណោយមួយចំនួនជូនដល់កងកម្លាំងប្រដាប់អាវុធនៅក្រុងសំរោង ខេត្តឧត្តរមានជ័យ។

ថ្ងៃអាទិត្យ ៩កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៥